# នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាល
# សាធារណរដ្ឋសង្គមនិយមវៀតណាម

លេខ: ១០១/LĐCP                                   ហាណូយ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤

*គោរពផ្ញើជូន: ជនរួមជាតិ សមមិត្តនិងព្រះសង្ឃខ្មែរគ្រប់ព្រះអង្គ*

បុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ គឺជាលក្ខណៈវប្បធម៌ដ៏ពិសេសរបស់ជនរួមជាតិ ជាពិធីបុណ្យធំបំផុតក្នុងឆ្នាំមានអត្ថន័យដ៏វិសេសវិសាល ចាប់ផ្តើមឈានចូលឆ្នាំថ្មីដោយក្តីជឿជាក់និងគោលបំណងប្រាថ្នា ជួបប្រទះតែសេចក្តីសុខ ជីវភាពសម្បូរសប្បាយ សុភមង្គល; ហើយក៏ជាឱកាសដើម្បីសម្តែងទឹកចិត្តកតញ្ញូ គោរពដឹងគុណចំពោះបុព្វការីជន។

ស្របក្នុងឱកាសនេះ ជំនួសមុខថ្នាក់ដឹកនាំបក្ស រដ្ឋ ខ្ញុំសូមគោរពផ្ញើជូនចំពោះជនរួមជាតិ សមមិត្ត និងព្រះសង្ឃខ្មែរគ្រប់ព្រះអង្គនូវមនោសញ្ចេតនាដ៏កក់ក្តៅ និងបិយវាចាសួរសុខទុក្ខដ៏ស្និទ្ធស្នាលជាទីបំផុត ព្រមទាំងប្រសិទ្ធពរឆ្នាំថ្មី បវរសួស្តីមហាប្រសើរ។

ជាមួយនឹងចំនួនមនុស្សជាង ១,៣ លាននាក់ ជនរួមជាតិខ្មែរជាផ្នែកមួយមិនអាចកាត់ផ្តាច់ពីសហគមន៍បណ្តាជនជាតិវៀតណាម មានតួនាទីដ៏សំខាន់ក្នុងបុព្វហេតុកសាងនិងការពារមាតុភូមិ។ រយៈពេលកន្លង ជនរួមជាតិខ្មែរតែងជឿជាក់និងអនុវត្តយ៉ាងម៉ឺងម៉ាត់រាល់គោលការណ៍របស់បក្ស គោលនយោបាយ ច្បាប់របស់រដ្ឋ រួមកម្លាំងកាយចិត្តជាមួយប្រជាជនទូទាំងប្រទេស រួមចំណែកយ៉ាងសកម្មនូវស្នាដៃ សមិទ្ធផលដ៏ធំធេង គ្រប់ជ្រុងជ្រោយរបស់ប្រទេសជាតិលើគ្រប់វិស័យ; តំបន់ជនរួមជាតិខ្មែរ មានជំហានអភិវឌ្ឍន៍ថ្មី ជីវភាពសម្ភារៈនិងស្មារតីរបស់ប្រជាជន បន្តបានលើកស្ទួយ។

ការងារជនជាតិ សាសនាគឺជាបញ្ហាយុទ្ធសាស្ត្រ តែងបានបក្ស រដ្ឋយើង យកចិត្តទុកដាក់ចង្អុលការយ៉ាងជិតដល់; ការអនុវត្តល្អនូវគោលនយោបាយជនជាតិ សាសនា ត្រូវបានចាត់ជាភារកិច្ចនយោបាយ មុខជំនាញដ៏សំខាន់របស់គណៈកម្មាធិការបក្ស រដ្ឋអំណាចគ្រប់លំដាប់ថ្នាក់ សំដៅពង្រឹងផែនមហាសាមគ្គីទូទាំងជនជាតិ បង្កើនការពង្រីកនូវតម្លៃជាវិជ្ជមាន មនុស្សធម៌របស់ជនរួមជាតិនៃបណ្តាជនជាតិ។ ចាប់ពីឆ្នាំ ២០១៨ រហូតមកទល់បច្ចុប្បន្ន ការងារជនជាតិត្រូវបានយកចិត្តទុកដាក់ជំរុញការផ្សព្វផ្សាយដោយមានគោលការណ៍ គោលនយោបាយធំៗជាច្រើន ក្នុងនោះ មានសេចក្តីសន្និដ្ឋានលេខ ៦៥-KL/TW ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៩ របស់ការិយាល័យនយោបាយ ស្តីពីការបន្តអនុវត្តសេចក្តីសម្រេចលេខ ២៤-NQ/TW របស់គណៈប្រតិបត្តិការមជ្ឈិម

បក្ស នីតិកាល IX ស្ដីពីការងារជនជាតិក្នុងស្ថានភាពថ្មី សេចក្តីសម្រេចចិត្តរបស់រដ្ឋសភា រដ្ឋាភិបាល សេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាល ស្ដីពីយុទ្ធសាស្រ្តការងារជនជាតិ ដំណាក់កាល ២០២១-២០៣០ ចក្ខុវិស័យដល់ឆ្នាំ ២០៤៥ កម្មវិធីទិសដៅជាតិអភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គម តំបន់ជនរួមជាតិភាគតិចនិងតំបន់ភ្នំ ដំណាក់កាល ២០២១-២០៣០; ពិសេស គណៈលេខាធិការមជ្ឈិមបក្ស បានប្រកាសដាក់ចេញជាធរមានបទបញ្ជាលេខ ១៩-CT/TW ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០១៨ ដើម្បីបង្កើនកិច្ចចង្អុលការការងារនៅតំបន់ជនរួមជាតិខ្មែរក្នុងស្ថានភាពថ្មី បង្ហាញពីការយកចិត្តទុក ដាក់ដ៏ជ្រាលជ្រៅរបស់បក្ស រដ្ឋ ចំពោះជនរួមជាតិភាគតិចនិយាយរួម និងជនរួមជាតិខ្មែរនិយាយដោយឡែក។

ដើម្បីបន្តការអនុវត្តល្អនូវគោលនយោបាយជនជាតិ សាសនា ផ្សារភ្ជាប់ជាមួយនឹង គោលនយោបាយសុខុមាលភាពសង្គមនៅពេលខាងមុខ គ្រប់ថ្នាក់ គ្រប់ផ្នែកនិងភូមិភាគទាំងអស់តំបន់មានជនរួមជាតិខ្មែររស់នៅកុះករ គប្បីម្ចាស់ការ រៀបរៀង ផ្ដុំកម្លាំងផ្សព្វផ្សាយអនុវត្តវិធានការឧបត្ថម្ភលើកកម្ពស់មុខរបររកស៊ីចិញ្ចឹមជីវិត កែលម្អជីវភាពសម្ភារៈ និងស្មារតីរបស់ប្រជាជន ធានាសមស្របជាមួយស្ថានភាពជាក់ស្ដែង ផ្ដោតការយកចិត្តទុកដាក់ចំពោះមុខសញ្ញាគោលនយោបាយអ្នកមានសគុណនិងសាច់ញាតិអ្នកមានសគុណចំពោះបដិវត្តន៍ គ្រួសារក្រីក្រ គ្រួសារមានជីវភាពលំបាក; ពង្រឹកតួនាទីរបស់ឥស្សរជន បញ្ញវន្ត អ្នកមានប្រជាប្រិយ និងមន្ត្រីសង្ឃជាជនរួមជាតិខ្មែរ។

ឆ្នាំ២០២៤ ជាឆ្នាំរៀបចំមហាសន្និបាតតំណាងបណ្តាជនជាតិភាគតិចថ្នាក់ស្រុក ថ្នាក់ខេត្ត លើកទី IV ជាព្រឹត្តិការណ៍នយោបាយ មានអត្ថន័យយ៉ាងជ្រាលជ្រៅ ដើម្បីបូកសរុប វាយតម្លៃពីការងារជនជាតិ និងការអនុវត្តនូវគោលនយោបាយជនជាតិក្នុងអំឡុងពេល ១០ ឆ្នាំ; បញ្ជាក់ពីគោលនយោបាយមិនងាករេរបស់បក្ស រដ្ឋយើងពីបញ្ហាជនជាតិនិងមហាសាមគ្គីជនជាតិ ក៏ដូចជាការរួមចំណែករបស់ជនរួមជាតិបណ្ដាជនជាតិភាគតិច ក្នុងបុព្វហេតុកសាងនិងការពារមាតុភូមិ បង្កជាកម្លាំងចលករអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយតំបន់ជនជាតិភាគតិច ក្នុងនោះ មានតំបន់ជនរួមជាតិខ្មែរធានានូវភាពជឿនលឿន សមភាពសង្គម និងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

ជាមួយនឹងអត្ថន័យនោះ ខ្ញុំជឿជាក់ថា បុណ្យចូលឆ្នាំថ្មី ២០២៤ នឹងផ្ដល់នូវភាពជឿជាក់និងក្ដីសង្ឃឹម បង្កបរិយាកាសសប្បាយរីករាយនិងកម្លាំងចលករថ្មី; ដោយជឿជាក់យ៉ាងមុតមាំថា ជនរួមជាតិ សមមិត្តនិងព្រះសង្ឃខ្មែរគ្រប់ព្រះអង្គនឹងបន្តពង្រឹកស្មារតីស្នេហាជាតិ ប្រពៃណីសាមគ្គី និងសមិទ្ធផលដ៏ល្អប្រសើរ ឆន្ទៈខ្លួនទីពឹងខ្លួន; លើកកម្ពស់គុណតម្លៃ គំនិតប្រាជ្ញា និងរបើកគំនិតច្នៃ

ប្រតិដ្ឋរបស់បុគ្គលម្នាក់ៗ ដើម្បីរួមកម្លាំងកាយចិត្តជាមួយនឹងជនរួមជាតិនៃបណ្តាជនជាតិ កសាងមាតុភូមិ ប្រទេសជាតិ កាន់តែសម្បូរសប្បាយ ស៊ីវិល័យ។

ខ្ញុំសំណូមពរដល់គ្រប់ថ្នាក់ គ្រប់ផ្នែក និងគ្រប់ភូមិភាគទាំងអស់ ត្រៀមលក្ខណសម្បត្តិឱ្យបានល្អជូនជនរួមជាតិខ្មែរ ទទួលអំណរបុណ្យចូលឆ្នាំថ្មី ឆ្នាំ២០២៤ ដោយភាពសាមគ្គី សប្បាយរីករាយ សមរម្យ សុវត្ថិភាព ប្រិតសំចៃ សមស្របជាមួយនឹងផ្ទត់រស់នៅស៊ីវិល័យ ទំនៀមទម្លាប់ប្រពៃណីវប្បធម៌ល្អប្រសើររបស់ជនជាតិ។

ជាថ្មីម្តងទៀត ខ្ញុំសូមប្រសិទ្ធពរដល់ជនរួមជាតិ សមមិត្ត ព្រះសង្ឃគ្រប់ព្រះអង្គ និងជនរួមជាតិខ្មែរគ្រប់ៗគ្រួសារ មានសុខភាពល្អបរិបូរ សប្បាយរីករាយ សុភមង្គលនិងជោគជ័យគ្រប់ភារកិច្ច៕

សូមអរគុណ

**ផាមមិញជិញ**

**THỦ TƯỚNG CHÍNH PHỦ**
**NƯỚC CỘNG HÒA XÃ HỘI CHỦ NGHĨA**
**VIỆT NAM**

Số: 101 /LĐCP

*Hà Nội, ngày 01 tháng 4 năm 2024*

***Thân ái gửi:* Đồng bào, đồng chí và các vị chư tăng dân tộc Khmer**

Tết cổ truyền Chôl Chnăm Thmây là nét văn hóa đặc sắc của đồng bào dân tộc Khmer, là lễ hội lớn nhất trong năm có ý nghĩa đặc biệt quan trọng, khởi đầu năm mới với niềm tin, khát vọng, cầu chúc cho sự tốt đẹp, cuộc sống ấm no, hạnh phúc; cũng là dịp thể hiện tấm lòng hiếu thảo, thành kính với tổ tiên.

Nhân dịp này, thay mặt lãnh đạo Đảng và Nhà nước, tôi thân ái gửi tới đồng bào, đồng chí và các vị chư tăng dân tộc Khmer tình cảm thân thiết, lời thăm hỏi ân cần và lời chúc mừng tốt đẹp nhất.

Với hơn 1,3 triệu người, đồng bào Khmer là một bộ phận không thể tách rời của cộng đồng các dân tộc Việt Nam, có vai trò quan trọng trong sự nghiệp xây dựng và bảo vệ Tổ quốc. Trong thời gian qua, đồng bào dân tộc Khmer đã luôn tin tưởng và nghiêm túc tuân thủ các chủ trương của Đảng, chính sách, pháp luật của Nhà nước, chung sức, đồng lòng với Nhân dân cả nước đóng góp tích cực vào những thành tựu, kết quả to lớn, toàn diện của đất nước trên mọi mặt; vùng đồng bào dân tộc Khmer có bước phát triển mới, đời sống vật chất, tinh thần của người dân tiếp tục được nâng cao.

Công tác dân tộc, tôn giáo là vấn đề chiến lược, luôn được Đảng, Nhà nước ta quan tâm chỉ đạo sát sao; việc thực hiện tốt chính sách dân tộc, tôn giáo được coi là nhiệm vụ chính trị, chuyên môn quan trọng của cấp ủy, chính quyền các cấp nhằm củng cố khối đại đoàn kết toàn dân tộc, tăng cường phát huy các giá trị tích cực, nhân văn của đồng bào các dân tộc. Từ năm 2018 đến nay, công tác dân tộc được chú trọng đẩy mạnh triển khai với nhiều chủ trương, chính sách lớn, trong đó có Kết luận số 65-KL/TW ngày 30 tháng 10 năm 2019 của Bộ Chính trị về tiếp tục thực hiện Nghị quyết số 24-NQ/TW của Ban Chấp hành Trung ương Đảng khóa IX về công tác dân tộc trong tình hình mới, các Nghị quyết của Quốc hội, Chính phủ, Quyết định của Thủ tướng Chính phủ về Chiến lược công tác dân tộc giai đoạn 2021 - 2030, tầm nhìn đến năm 2045, Chương trình mục tiêu quốc gia phát triển kinh tế - xã hội vùng đồng bào dân tộc thiểu số và miền núi giai đoạn 2021 - 2030; đặc biệt Ban Bí thư đã ban hành riêng Chỉ thị số 19-CT/TW ngày 10 tháng 01 năm 2018 để tăng cường chỉ đạo công tác ở vùng đồng bào dân tộc Khmer trong tình hình mới, thể hiện sự quan tâm sâu sắc của Đảng, Nhà nước tới đồng bào dân tộc thiểu số nói chung và đồng bào dân tộc Khmer nói riêng.

Để tiếp tục thực hiện tốt chính sách dân tộc, tôn giáo gắn liền với các chính sách an sinh xã hội trong thời gian tới, các cấp, các ngành và địa phương nơi có đồng bào dân tộc Khmer sinh sống cần chủ động, linh hoạt, tập trung triển khai các giải pháp hỗ trợ nâng cao sinh kế, cải thiện đời sống vật chất và tinh thần của người dân bảo đảm phù hợp tình hình thực tiễn, chú trọng quan tâm các đối tượng chính sách, người có công và thân nhân người có công với cách mạng, hộ nghèo, gia đình có hoàn cảnh khó khăn; phát huy vai trò của nhân sĩ, trí thức, người có uy tín, các vị chức sắc trong đồng bào dân tộc Khmer.

Năm 2024 là năm tổ chức Đại hội đại biểu các dân tộc thiểu số cấp huyện, cấp tỉnh lần thứ IV, sự kiện chính trị có ý nghĩa quan trọng để tổng kết, đánh giá về công tác dân tộc và việc thực hiện chính sách dân tộc định kỳ 10 năm; khẳng định đường lối nhất quán của Đảng và Nhà nước ta về vấn đề dân tộc và đại đoàn kết dân tộc cũng như những đóng góp của đồng bào các dân tộc thiểu số trong sự nghiệp xây dựng và bảo vệ Tổ quốc, tạo động lực phát triển toàn diện vùng đồng bào dân tộc thiểu số, trong đó có vùng đồng bào dân tộc Khmer, bảo đảm tiến bộ, công bằng xã hội và sự phát triển bền vững đất nước.

Với ý nghĩa đó, tôi tin tưởng rằng, Tết Chôl Chnăm Thmây 2024 sẽ mang đến niềm tin và hy vọng, tạo không khí phấn khởi và động lực mới; tin tưởng rằng đồng bào, đồng chí và các vị chư tăng dân tộc Khmer sẽ tiếp tục phát huy tinh thần yêu nước, truyền thống đoàn kết và những giá trị tốt đẹp, ý chí tự lực, tự cường; đề cao phẩm giá, trí tuệ và khai mở sức sáng tạo của mỗi cá nhân để chung sức, đồng lòng cùng đồng bào các dân tộc xây dựng quê hương, đất nước ngày càng giàu đẹp, văn minh.

Tôi đề nghị các cấp, các ngành, các địa phương chuẩn bị tốt các điều kiện cho đồng bào dân tộc Khmer đón tết Chôl Chnăm Thmây năm 2024 đoàn kết, vui tươi, lành mạnh, an toàn, tiết kiệm, phù hợp với nếp sống văn minh, phong tục, tập quán, truyền thống văn hóa tốt đẹp của dân tộc.

Một lần nữa, tôi xin chúc đồng bào, đồng chí, các vị chư tăng dân tộc Khmer sức khỏe, an lành, hạnh phúc và thành công.

*Chào thân ái!*

**Phạm Minh Chính**